## ចលនាមាតាធម្មជាតិទទួលបានពានរង្វាន់ដ៏មានកិត្តិយសពីអង្គការ Right Livelihood ក្នុងការការពារធនធានធម្មជាតិ និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ

**ទីក្រុងស្តុកហូម - ចលនាមាតាធម្មជាតិ ដែលជាចលនាដឹកនាំដោយយុវជនក្នុងការការពារសិទ្ធិបរិស្ថាន គឺស្ថិតនៅក្នុងចំណោមម្ចាស់ជ័យលាភីដ៏ទៃទៀតដើម្បីទទួលពានរង្វាន់ Right Livelihood ក្នុងឆ្នាំ២០២៣នេះ ចំពោះវីរភាពដ៏ក្លាហានរបស់ពួកគេក្នុងកិច្ចការពារបរិស្ថាន។ ពួកគេការពារធនធានធម្មជាតិរបស់ប្រទេសកម្ពុជា លើកកម្ពស់សិទ្ធិមនុស្ស និងលិទ្ធិប្រជាធិបតេយ្យ ដោយត្រូវប្រឈមមុខនឹងការបង្រ្កាបជាបន្តបន្ទាប់ពីសំណាក់រដ្ឋាភិបាល។**

អស់រយៈពេលជាង៤០ឆ្នាំមកនេះ ពានរង្វាន់ Right Livelihood ត្រូវបានផ្តល់ និងគាំទ្រដល់បុគ្គលនានាដែលមានភាពក្លាហានក្នុងការដោះស្រាយបញ្ហាសកល។ មកទល់បច្ចុប្បន្ន ម្ចាស់ជ័យលាភីចំនួន១៩៤នាក់/អង្គការ មកពី៧៦ប្រទេសបានទទួលពានរង្វាន់នេះ ដែលក្នុងនោះរួមមានសកម្មជនបម្រែបម្រួលអាកាសធាតុស៊ុយអែត Greta Thunberg អ្នកការពារសិទ្ធិមនុស្សអ៊ុយក្រែន Oleksandra Matviichuk អ្នកតស៊ូមតិដើម្បីសិទ្ធិស្ត្រីកុងហ្គោ និងជាវេជ្ជបណ្ឌិត Denis Mukwege។

ដោយមិនមានការរុញរា ទោះបីជាទទួលរងហានិភ័យ ការរំលោភបំពាន និងការចាប់ខ្លួនជាច្រើនលើកក្តី ចលនាមាតាធម្មជាតិបានលេចចេញជាចលនាដ៏មានឥទ្ធិពលក្នុងការអភិរក្សបរិស្ថាន និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ចលនានេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១២ ដោយបានទទួលជោគជ័យក្នុងការជួយដល់សហគមន៍មូលដ្ឋានក្នុងការបញ្ឈប់ការរំលោភបំពានបរិស្ថានជាអាទិ៍រួមមាន ការសាងសង់ទំនប់វារីអគ្គិសនីដែលគម្រាមកំហែងដល់សហគមន៍ជនជាតិដើមភាគតិច និងជំនួញនាំចេញខ្សាច់ដ៏ពុករលួយទៅក្រៅប្រទេស។

ដោយធ្វើប្រតិបត្តិការក្នុងបរិបទសង្គមមួយដែលមានការគាបសង្កត់ ការប្រើប្រាស់សិទ្ធិបញ្ចេញមតិត្រូវបានចាត់ទុកថាជាការវាយប្រហាររដ្ឋាភិបាល។ ចលនាមាតាធម្មជាតិបាននាំអារម្មណ៍សាធារណៈជនឱ្យមើលឃើញនូវសហគមន៍ងាយរងគ្រោះ និងសហគមន៍ដែលត្រូវបានគេបោះបង់ចោលក្នុងប្រទេសកម្ពុជា។ តាមរយៈភាពក្លាហានរបស់ពួកគេ ប្រាកដណាស់ ចលនាមាតាធម្មជាតិបានផ្លាស់ប្តូរនូវទិដ្ឋភាពនៃសង្គមស៊ីវិលកម្ពុជា ដោយបន្លឺសម្លេងអំពីកង្វល់ផ្នែកបរិស្ថាន និងសិទ្ធិមនុស្សតាមរយៈវិធីស្រាស្រ្តដឹកនាំដោយយុវជនពោរពេញដោយភាពច្នៃប្រឌិត ដែលបានពង្រីកលំហសិទ្ធិពលរដ្ឋ និងផ្តល់ក្តីសង្ឃឹមដល់ក្មេងជំនាន់ក្រោយក្នុងការផ្លាស់ប្តូរជាវិជ្ជមាន។

គណៈកម្មការក្នុងការផ្តល់ពានរង្វាន់ Right Livelihood បានលើកឡើងថា ពានរង្វាន់នេះត្រូវបានផ្តល់ឱ្យចលនាមាតាធម្មជាតិសម្រាប់ “ភាពក្លាហាន និងភាពទាក់ទាញរបស់ពួកគេក្នុងការអភិរក្សបរិស្ថានធម្មជាតិនៅក្នុងបរិបទសង្គមមួយដែលលំហប្រជាធិបតេយ្យត្រូវបានរិតត្បិតក្នុងកម្រិតធ្ងន់ធ្ងរ។”

“ពានរង្វាន់នេះមិនមែនត្រឹមតែជារបស់ក្រុមការងារចលនាមាតាធម្មជាតិទេ ប៉ុន្តែក៏ជារបស់ប្រជាពលរដ្ឋខ្មែរ ដែលជានិច្ចជាកាលតែងតែគាំទ្រ និងលើកទឹកចិត្តពួកយើង”- អ្នកនាង

Right
Livelihood

ស៊ុន រដ្ឋា សមាជិកចលនាមាតាធម្មជាតិ ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ ដែលបានជាប់ពន្ធនាគារចំនួន៥ខែ ព្រោះតែសកម្មភាពការពារបរិស្ថានរបស់គាត់កាលពីឆ្នាំ២០២១។

សកម្មជនបរិស្ថានម្នាក់ទៀតគឺ លោក លី ចាន់ដារ៉ាវុត ដែលបានជាប់ពន្ធនាគារ៥ខែដូចគ្នាដែរ បានលើកឡើងថា "មេដឹកនាំផ្តាច់ការរមែងចង់ឱ្យពួកយើងនៅឱ្យឆ្ងាយពីនយោបាយ នៅឱ្យឆ្ងាយពីលទ្ធិប្រជាធិបតេយ្យ និងជៀសវាងការរិះគន់ទៅលើរដ្ឋាភិបាល។ ពានរង្វាន់នេះគឺជាសក្ខីភាព ដែលបញ្ជាក់ថា ពួកយើងមានសិទ្ធិក្នុងការការពារប្រទេសជាតិរបស់ខ្លួន ក្នុងនាមជាសកម្មជន ហើយវាជាកាតព្វកិច្ចរបស់ពួកយើងក្នុងការប្រើប្រាស់សិទ្ធិនេះ"។

សកម្មជនទាំង២រូបខាងលើ គឺកំពុងតែរង់ចាំការជំនុំជម្រះពាក់ព័ន្ធនឹងបទចោទប្រកាន់ពីបទរួមគំនិតក្បត់ (ប្រឆាំងនឹងរដ្ឋាភិបាល) និងប្រមាថព្រះមហាក្សត្រ ដែលអាចជាប់ពន្ធនាគាររហូតដល់១០ឆ្នាំ។

**សកម្មជនចលនាមាតាធម្មជាតិនឹងធ្វើសន្និសីទកាសែតមួយនៅថ្ងៃទី២៨ ខែកញ្ញានេះ ចាប់ផ្តើមពីម៉ោង ៩៖ ៣០នាទី ព្រឹក CEST (ម៉ោងអឺរ៉ុប) ត្រូវនឹងម៉ោងកម្ពុជា ១៤៖ ៣០ នាទីរសៀល។** **សូមចុះឈ្មោះនៅទីនេះ!**

"ចលនាមាតាធម្មជាតិគឺជាក្រុមសកម្មជនវ័យក្មេងដ៏ក្លាហាន ដែលកំពុងតស៊ូដើម្បីសិទ្ធិបរិស្ថាន និងលិទ្ធិប្រជាធិបតេយ្យ ដោយត្រូវប្រឈមមុខនឹងការគាបសង្កត់ពីសំណាក់របបដឹកនាំរបស់ប្រទេសកម្ពុជា" -លើកឡើងដោយលោក Ole Von Uexkull នាយកប្រតិបត្តិនៃអង្គការ Right Livelihood។ "តាមរយៈសកម្មភាពសាធារណៈពោរពេញដោយភាពច្នៃប្រឌិត និងភាពសប្បាយរីករាយ សកម្មភាពរបស់ពួកគេបានរួមចំណែកការពារបរិស្ថាន និងជីវភាពរស់នៅ ព្រមទាំងលើកកម្ពស់សម្លេងសហគមន៍ប្រឆាំងនឹងអំពើពុករលួយ និងគម្រោងបំផ្លាញបរិស្ថាន។ ទោះបីជាមានការចាប់ខ្លួន ការធ្វើទុក្ខបុកម្នេញតាមផ្លូវច្បាប់ និងការតាមឃ្លាំមើលក្តី ពួកគេនៅតែបន្តតស៊ូយ៉ាងអង់អាចដើម្បីលើក កម្ពស់សិទ្ធិពលរដ្ឋ និងសិទ្ធិបរិស្ថានរបស់ប្រទេសកម្ពុជា"។

ចលនាមាតាធម្មជាតិគឺជាម្ចាស់ពានរង្វាន់ Right Livelihood ដំបូងគេបំផុតនៅក្នុងប្រទេសកម្ពុជា។

ម្ចាស់ពានរង្វាន់ផ្សេងទៀតក្នុងឆ្នាំ២០២៣នេះរួមមាន៖

- SOS MEDITERRANEE (សន្និសីទអនឡាញនាម៉ោង ១០៖ ៣០ ដល់ម៉ោង១១៖ ០០ នាទីព្រឹក CEST)
- Phyllis Omido ពីប្រទេសកេនយ៉ា (សន្និសីទអនឡាញនាម៉ោង ១១៖ ៣០ព្រឹក ដល់ម៉ោង១២៖ ០០ថ្ងៃត្រង់ CEST)
- Eunice Brookman-Amissah ពីប្រទេសហ្កាណា (សន្និសីទអនឡាញនាម៉ោង ១៖ ០០ នាទីរសៀល ដល់ម៉ោង១៖ ៣០ នាទីរសៀល CEST)

សូមចុះឈ្មោះដើម្បីចូលរួមសន្និសីទកាសែតនៅទីនេះ។

ម្ចាស់ពានរង្វាន់កាលពីឆ្នាំ២០២២ នឹងត្រូវបានផ្តល់កិត្តិយសកំឡុងពេលធ្វើបទបង្ហាញអំពីពានរង្វាន់តាមទូរទស្សន៍ក្នុងទីក្រុងស្តុកហូម នៅថ្ងៃពុធ ទី២៩ ខែវិច្ឆិកានេះ។

ស្វែងរកព័ត៌មានបន្ថែមអំពីម្ចាស់ជ័យលាភីនៅទីនេះ។

រូបភាព និងវីដេអូរបស់ម្ចាស់ជ័យលាភីរកបាននៅទីនេះ។


ទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយ

សម្រាប់ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ៖ : Emoke Bebiak, emoke.bebiak@rightlivelihood.org, +41 78 333 84 84 និង Sydney Nelson, sydney.nelson@rightlivelihood.org, +46 73 043 13 01

សម្រាប់ប្រព័ន្ធផ្សព្វផ្សាយអាល្លឺម៉ង់៖ Julia Naumann និងNina Tesenfitz, presse@rightlivelihood.org,

+49 170 5763 663

សម្រាប់ប្រព័ន្ធផ្សព្វផ្សាយអេស្ប៉ាញ៖ Nayla Azzinnari, nayla@rightlivelihood.org, +54 9 11 5460 9860

សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ Scandinavian៖ Johannes Mosskin, johannes@rightlivelihood.org, +46 70 437 11 48

សម្រាប់ប្រព័ន្ធផ្សព្វផ្សាយអឺរ៉ុបខាងកើត៖ Marina Shupac, marina.shupac@rightlivelihood.org,

+41 76 746 13 59

សម្រាប់រូបភាព និងវីដេអូ៖ Mikaela Fredrikson, mikaela.fredrikson@rightlivelihood.org

Photos, videos: Mikaela Fredrikson, mikaela.fredrikson@rightlivelihood.org


ជីវប្រវត្តិខ្លី

ចលនាមាតាធម្មជាតិ គឺជាចលនាយុវជនការពារសិទ្ធិបរិស្ថានដ៏លេចធ្លោជាងគេ ដែលធ្វើការនៅជួរមុខជាមួយ សហគមន៍មូលដ្ឋានក្នុងការការពារធនធានធម្មជាតិ និងជីវភាពរស់នៅរបស់ពួកគេ បើទោះបីជាត្រូវប្រឈមជាមួយការធ្វើទុក្ខម្នេញជាបន្តបន្ទាប់ពីសំណាក់រដ្ឋាភិបា

លទៅលើវិស័យសង្គមស៊ីវិលក្តី។ ដោយប្រើប្រាស់ភាពច្នៃប្រឌិតក្នុងការផលិតវីដេអូ ដែលមានអ្នកទស្សនាច្រើនសែននាក់ ការផ្តល់វគ្គបណ្តុះបណ្តាល និងការប្រមូលផ្តុំយុវជនខ្មែរទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ចលនាមាតាធម្មជាតិបានជួយរំលេចឱ្យឃើញ និងព្យាយាមបញ្ឈប់ការបំផ្លិចបំផ្លាញធនធានធម្មជាតិ។ យុទ្ធនាការណ៍ដែលទទួលបានជោគជ័យរួមមាន ការបញ្ឈប់គម្រោងសាងសង់ទំនប់វារីអគ្គិសនីដោយក្រុមហ៊ុនចិន ដែលគម្រាមកំហែងដល់សហគមន៍ជនជាតិដើមភាគតិច និងការបញ្ឈប់ជំនួញបូមខ្សាច់តាមព្រែកនានានៅខេត្តកោះកុង ដែលពោរពេញទៅដោយភាពពុករលួយ ការបំផ្លាញដល់ជីវចម្រុះក្នុងតំបន់ និងជម្រកត្រីសម្រាប់នេសាទ។

បង្កើតឡើងក្នុងឆ្នាំ២០១២ ក្រុមការងារស្នូល ដែលមានទំហំតូច និងភាពបត់បែន របស់ចលនាមាតាធម្មជាតិបានធ្វើការតៀងតរប្រឆាំងនឹងការសាងសង់ទំនប់វារីអគ្គិសនី និងគម្រោងសាងសង់ដែលមានភាពពុករលួយផ្សេងៗទៀត។ ជាសូចនាករក្នុងការបង្ហាញអំពីជំហរប្រឆាំង និងមិនគាំទ្ររបស់រដ្ឋាភិបាលដល់ចលនានេះ សកម្មជនចលនាមាតាធម្មជាតិចំនួន១១នាក់ត្រូវបានចាប់ខ្លួនដាក់ពន្ធនាគារ និងសកម្មជនរាប់សិបនាក់ត្រូវបានចាប់ចងតាំងពីឆ្នាំ២០១៥មក ខណៈពេលដែលសមាជិកម្នាក់ និងស្ថាបនិករបស់ចលនានេះ លោកអាឡិចហាន់ដ្រូ ហ្គន់ហ្សាលេស ដាវីតសុន ត្រូវបានបង្ខំឱ្យចាកចេញពីប្រទេសកម្ពុជា។ សហគមន៍មូលដ្ឋាន ដែលបានធ្វើយុទ្ធនាការ និងធ្វើការជាមួយចលនាមាតាធម្មជាតិក៏ត្រូវបានគំរាមកំហែង ការប្រើប្រាស់ប្រព័ន្ធតុលាការក្នុងការធ្វើទុក្ខបុកម្នេញ និងការតាមឃ្លាំមើលពីសំណាក់ប៉ូលិសដូចគ្នាដែរ។

ទោះបីជាមានការរំលោភបំពាន និងហានិភ័យនៃការចាប់ខ្លួនជាបន្តបន្ទាប់ក្តីក៏ចលនាមួយនេះនៅតែបន្តឧត្តមគតិរបស់ខ្លួន និងនៅតែធ្វើយុទ្ធនាការណ៍ការពារបរិស្ថានយ៉ាងក្លាហាន។ ដោយធ្វើការកត់សំគាល់អំពីទំនាក់ទំនងរវាងលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងកិច្ចការពារបរិស្ថាន ចលនាមាតាធម្មជាតិបានលេចឡើងជាពន្លឺនៃក្តីសង្ឃឹមសម្រាប់យុវជនជំនាន់ក្រោយក្នុងការតស៊ូការពារធនធានធម្មជាតិ និងសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា។

**សម្រាប់ពត៌មានអំពីជីវប្រវត្តិចលនាមាតាធម្មជាតិ**

**ទីតាំង៖** ប្រទេសកម្ពុជា

**បង្កើតឡើង៖** ឆ្នាំ២០១២

**វេបសាយ៖** https://mothernaturecambodia.org/

Facebook: https://www.facebook.com/mothernaturecambodia/

**អំពី Right Livelihood**

អស់រយៈពេលជាង៤០ឆ្នាំមកនេះ Right Livelihood បានធ្វើការផ្តល់ពានរង្វាន់ និងគាំទ្រដល់បុគ្គលក្លាហានក្នុងការចូលរួមដោះស្រាយបញ្ហាសកល។ ដោយស្ថិតក្រោមឆ័ត្រនៃមូលនិធិ Right Livelihood គឺជាសហគមន៍ដែលជម្រុញដោយភាពក្លាហានដើម្បីការផ្លាស់ប្តូរសង្គមដោយប្តេជ្ញាចិត្តទៅលើសន្តិភាព យុត្តិធម៌ និងចីរភាពសម្រាប់បុគ្គលគ្រប់រូប។

Right Livelihood

ជារៀងរាល់ឆ្នាំ Right Livelihood បានធ្វើការកត់សម្គាល់បុគ្គលផ្លាស់ប្តូរសង្គមជាវិជ្ជមានតាមរយៈការផ្តល់ពានរង្វាន់។ មកទល់សព្វថ្ងៃនេះ ម្ចាស់ពានរង្វាន់ចំនួន១៩៤នាក់/អង្គការ មកពី៧០ប្រទេសបានទទួលពានរង្វាន់នេះ។ ដោយទទួលស្គាល់អំពីសកម្មភាពក្លាហាន ចក្ខុវិស័យ និងការកសាងទំនាក់ទំនងដ៏មានឥទ្ធិពលជុំវិញពិភពលោក Right Livelihood ជម្រុញឱ្យមានការផ្លាស់ប្តូរសង្គមជាបន្ទាន់ និងមាននិរន្តរភាព។

ពានរង្វាន់នេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៨០ ក្រោយពីម្ចាស់មូលនិធិពានរង្វាន់ណូបែលបដិសេធសំណើរក្នុងការបង្កើតពានរង្វាន់ថ្មី២ ដើម្បីផ្តល់ទៅឱ្យបុគ្គលដែលប្តេជ្ញាចិត្តក្នុងការជម្រុញឱ្យមានយុត្តិធម៌សង្គម និងបុព្វហេតុបរិស្ថាន ជាពិសេសរំលេចនូវបុគ្គលដែលជម្រុញឱ្យមានការផ្លាស់ប្តូរនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

សព្វថ្ងៃ ការងាររបស់ Right Livelihood គឺលើសពីការផ្តល់ពានរង្វាន់ទៅទៀត។ មូលនិធិរបស់ពួកយើងផ្តល់ឱ្យម្ចាស់ជ័យលាភីនូវការគាំទ្រពេញមួយជីវិត។ Right Livelihood គឺជាកន្លែងសម្រាប់បំពងសម្លេង និងជាខែលការពារ(ម្ចាស់ជ័យលាភី)៖ ការលើកស្ទួយប្រវត្តិរូបរបស់ពួកគេ អាចផ្តល់នូវការការពារនៅពេលដែលជីវិត និងសេរីភាពរបស់ពួកគេស្ថិតក្នុងភាពគ្រោះថ្នាក់ និងបង្រៀនដល់ប្រជាជនផ្សេងទៀតអំពីដំណោះស្រាយដ៏ច្នៃប្រឌិតរបស់ពួកគេផងដែរ។

Right Livelihood មានទីស្នាក់ការកណ្តាលនៅក្នុងទីក្រុងស្តុកហូម និងការិយាល័យមួយនៅទីក្រុងហ្សឺណែវ។ មូលនិធិនេះមានឋានៈជាអ្នកប្រឹក្សាយោបល់ (Consultative Status) ដល់អង្គការសហប្រជាជាតិ។

Right
Livelihood